# ចម្លាក់សត្វហេមពាន្តនៅវត្តដំរីស

## ១- ព័ត៌មានទូទៅ

ហេមពាន្ត ជាឈ្មោះភ្នំស្ថិតនៅប្រទេសភារតបច្ចុប្បន្ន។ កន្លងមកឈ្មោះភ្នំហេមពាន្ត មានសេចក្តីបរិយាយជាច្រើននៅក្នុងគម្ពីរជាតកបាលីនិងសម្រាយ នៅក្នុងសាស្ត្រាល្បែង និងពាក្យសរសើរពុទ្ធបាទដែលមានន័យច្រើន ហើយប្លែកៗខុសពីគ្នាទៀតផង។ ទោះបីជាយ៉ាងនេះក្តី ភ្នំហេមពាន្តគឺសម្គាល់ទៅលើភ្នំដែលមានព្រៃស្រោងស្រាងមានដើមឈើសព្វគ្រប់ប្រការ លាយឡំទៅដោយពួកសត្វកម្រៗមាន៖ កិន្នរ កេសរាជសីហ៍ ហត្ថីលិង្គ ដំរីឧបោសថ ផ្លែនារីផល និងសត្វប្លែកៗជាច្រើនប្រភេទ និងដើមព្រីងជាឈ្មោះរបស់ជម្ពូទ្វីប។ បើតាមសេចក្តីរៀបរាប់ក្នុងសាស្ត្រាល្បែងភ្នំហិមពាន្តគឺជាស្ថានលំនៅរបស់ពួកគ្រុឌ យក្ស វិទ្យាធរ តាបស ឥសី អ្នកព្រតសីល ម្រឹគពាលយ់ងឃ្នង សត្វបក្សាបក្សីគ្រប់ជំពូក។ តួយ៉ាងរឿងព្រះចន្ទគោរពនាងមុច្ចលិន ព្រះចន្ទគោរពបានទៅរៀនមន្តវិជ្ជាសិល្ប៍សាស្ត្រពីឥសីដែលគង់ក្នុងព្រៃហេមពាន្ត។ ចន្ទលិវង្សជាបុត្រព្រះចន្ទគោរពធ្វើដំណើរស្វែងរកបិតា ជីតាបានផ្តាំឱ្យប្រយ័ត្នតាមដងព្រៃហេមពាន្តព្រោះមានម្រឹគពាលយង់ឃ្នង សត្វបក្សាបក្សីមកបន្ទាចយំធ្វើជាសំឡេងគួរខ្លាចញ័ររន្ធត់។[១] ចំណែករឿងចៅរាជកុល គ្រាកាលនាងពៅជាអគ្គមហេសីចៅរាជកុល ដើរទៅរកប្តីដល់ព្រៃហេមពាន្តបានជួបពួកវិទ្យាធរ ជួបយក្សជួយយកអាសារនាង។[២] ស្របគ្នានេះក្នុងសមុទ្ទឃោសជាតក កាលព្រះសមុទ្ទឃោសនាំមហេសីហោះទៅព្រៃហេមពាន្ត បានជួបវិទ្យាធរឈ្មោះគ្នាជាអកុសលត្រូវពួកវិទ្យាធរលួចព្រះខ័នទិព្វព្រះអង្គធ្វើឱ្យព្រះអង្គហោះមកនគរវិញមិនរួច។[៣] ក្រៅពីនេះអ្នកនិពន្ធតែងតែពណ៌នារៀបរាប់ពីព្រៃឈើ សត្វបក្សាបក្សី មច្ឆា វារីជាតិ ដែលដុះនៅក្នុងព្រៃហេមពាន្តសឹងតែមានក្នុងប្រទេសខ្មែរខ្លះ និងខ្លះទៀតក៏មិនមាន។ ក្នុងដំណើររៀបរាប់ដដែលនេះ

---

[១] សូមអាន៖ សាស្ត្រាចន្ទគោរព នាងមុច្ចលិនខ្សែ២

[២] សូមអាន៖ សាស្ត្រារាជកុលខ្សែ២

[៣] សូមអាន៖ សាស្ត្រាព្រះសមុទ្ទឃោសខ្សែ១

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ឈ្មោះឈើខ្លះប្រែពីបាលី ឈ្មោះឈើខ្លះទៀតជាឈើស្រុក សត្វចតុប្បាទ គឺពួកម្រឹគ ដំរី រាជសីហ៍ រស់នៅជាហ្វូងៗជាច្រើនប្រភេទនិងទិដ្ឋភាពស្រះឆទ្ទន្ត[៨] ហ្វូងសត្វទាំងគួរគួរស្ញប់ស្ញែងអស្ចារ្យក្នុងចិត្ត។ ដូច្នេះភាពអស្ចារ្យនៃព្រៃហេមពាន្តនៅក្នុងសាស្ត្រាល្បែងក្តី ក្នុងគម្ពីរត្រៃភូមិក្តី សុទ្ធតែលើកតាមទស្សនៈសាសនា ព្រោះនៅក្នុងទស្សនៈសាសនាទេពនិករមានលំនៅឯស្ថានសួគ៌ និងនៅតាមដើមឈើជាពិសេសលើភ្នំហេមពាន្ត។ កាលណាគេនិយាយពីលោកធាតុគេនឹកដល់ភ្នំព្រះសុមេរុជាធំ។ កាលណាគេនិយាយពីនិទានជាតក តាបសឥសី វិទ្យាធរ បុប្ផា ផ្កាឈើ ផ្លែឈើ គេនឹងនឹកឃើញភ្នំហេមពាន្តមុនគេ ដែលជាស្ថានមួយស្ថិតនៅដាច់ដោយឡែកផ្សេងពីស្ថានមនុស្ស។ ដើម្បីស្តែងពីលក្ខណៈដាច់ដោយឡែកពីស្ថានមនុស្សឱ្យកាន់តែច្បាស់ គេត្រូវលើកបង្ហាញពីអ្វីដែលមាននៅភ្នំហេមពាន្តស្តែងឱ្យឃើញកន្លែងនោះពុំមែនជាស្ថានមនុស្សធម្មតាឡើយ។

## ២- ចម្លាក់សត្វហេមពាន្តនៅព្រះវិហារវត្តដំរីស

ព្រះវិហារគឺជាសំណង់សំខាន់មួយក្នុងសិល្បៈពុទ្ធសាសនាខ្មែរ វត្តនីមួយៗត្រូវមានព្រះវិហារសម្រាប់ព្រះសង្ឃធ្វើកម្ម និងតម្កល់ព្រះជីវ៍។ ព្រះវិហារគេតែងបិទជិតមិនគេបើកនៅពេលមានកិច្ចណាមួយដូចជាធ្វើសង្ឃកម្ម និងបន់ស្រន់។ ដូច្នេះហើយព្រះវិហារប្រៀបបានជាស្ថានមួយដាច់ដោយឡែកពីស្ថានមនុស្ស ក្រៅពីប្រព័ន្ធជំនឿយើងអាចឃើញតាមរយៈស្ថានទី របងរាជវ័តិ ក្លោងទ្វាររបស់ព្រះវិហារសុទ្ធតែជានិមិត្តរូបនៃស្ថានទេពមើលដូចជាខណ្ឌដាច់ពីគ្នារវាងស្ថានមនុស្សនិងព្រះ តាមរយៈសិល្បៈចម្លាក់ គំនូរ និងស្ថាបត្យកម្ម។ ករណីនេះយើងសូមបង្ហាញពីការស្តែងឱ្យឃើញស្ថានព្រះតាមរយៈចម្លាក់កំបោរបាយអរលើសសរជញ្ជាំងខឿនជាន់ទីមួយជុំវិញព្រះវិហារក្នុងវត្តដំរីសខេត្តបាត់ដំបង។ រូបសិល្បៈដូចជា៖ នាគ គ្រុឌ កិន្នរ យក្ស និងរូបសត្វហេមពាន្តជាច្រើនទៀតនៅកសាងនៅសម័យលោកម្ចាស់ឆ្នាំ១៩០៤ដោយក្រុមជាងកុង តូ ជាងស្នា ជាងញឹក ជាងសឿន ជាងអុន។[៩]

---

[៨] ឈ្មោះស្រះនេះហៅថាតាមឈ្មោះពូជដំរីឆទ្ទន្ត។

[៩] សូមអាន៖ តូច ឈួង បាត់ដំបងសម័យលោកម្ចាស់ (?) ឆ្នាំ១៩៩៤

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



ទីតាំងចម្លាក់សត្វហេមពាន្ត

ចម្លាក់សត្វហេមពាន្តនៅតាមខឿនព្រះវិហារគឺជាទឹកដៃក្រុមជាងរបស់លោកម្ចាស់សាងយ៉ាងវិចិត្ររស់រវើក អ្វីគួរឱ្យចាប់អារម្មណ៍គឺរូបរាងសត្វទាំងនោះយើងពុំសូវឃើញមានក្នុងចម្លាក់ពីមុនមក។ ជាងនេះទៅទៀតចម្លាក់សត្វទាំងនោះរូបជាសត្វស្លាបច្រើនជាងរូបជាសត្វចតុប្បាទ។ រូបនីមួយៗពុំមានចារឹកប្រាប់ឈ្មោះឡើយ ចំពោះការកំណត់ឈ្មោះនៅក្នុងទីនេះយើងកំណត់តាមសេចក្ដីអធិប្បាយ និងការផ្ទៀបរូបក្នុងគម្ពីរត្រៃភូមិ(ភាសាខ្មែរ) និងតម្រារូបសត្វហេមពាន្ត(ភាសាថៃ)។



ទណ្ឌមា



ពានរម្រឹគ



សិន្ធុបក្សី



កបិលបក្សា



ហង្សចិន



គីលែនបក្សី

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



អសុរៈវាយោភ័ក្ត្រ



សុបណ្ណ



មយូរវេនត្រៃ



សុបណ្ណហេរា



ហស្ដីលិង្គ



មាន់តាំងគា



មារីស



មច្ឆានព្វ



សិង្ហពានរ

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



មាន់ហុកកៀន



មាន់សេហួន



រាជហង្ស



គម្ពីរនិម្មិត



អសុរៈបក្សា



អប្សរសីហៈ



ទេពនរសិង្ហ



ទេស



កិន្នរ

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



(?)



(?)



(?)

ដើម្បីដឹងថារូបនេះមានឈ្មោះអ្វីខ្លះ យើងបានប្រៀបធៀបរូបសត្វហេមពាន្តទាំងអស់នេះនឹងរូបសត្វហេមពាន្តដែលមានក្នុងក្រាំងតម្រាសត្វហេមពាន្ត(ភាសាថៃ) គម្ពីរត្រៃភូមិ(ច្បាប់ភាសាខ្មែរ) គម្ពីរត្រៃភូមិ(ច្បាប់ភាសាថៃ) និងសមុតភាពរូបសត្វហេមពាន្ត(ភាសាថៃ)។ តាមរយៈការប្រៀបធៀបនេះយើងឃើញថារូបភាគច្រើនមានក្នុងក្រាំងតម្រាសត្វហេមពាន្តជាក្រាំងបុរាណចារនៅព.ស.២៤៥៥ដែលមានដូចជា៖ ហង្សចិន មារីសៈ សុវណ្ណហេរា កបិលយក្សា មច្ឆានព្វ នរសិង្ហ ពានរម្រឹគ មយូរវេនត្រៃ អសុរវាយោភ័ក្ត្រ អសុរបក្សី អប្សរសីហៈ ទណ្ឌមា សិន្ធុបក្សី គម្ពីរនិម្មិត មាន់ហុកកៀន មាន់សេហ្វួន មាន់តាំងគា។[៦] រូបសត្វក្នុងគម្ពីរត្រៃភូមិខ្មែរមានដូចជា៖ រាជហង្ស សុបណ្ណ គីលែនបក្សី ហស្ដីលិង្គ។ ចំពោះរូបសត្វដែលមានសញ្ញា(?)គឺជារូបសត្វដែលយើងពុំអាចកំណត់ឈ្មោះបានព្រោះមិនមានរូបណាមួយអាចប្រៀបនឹងគ្នាឡើយ។

សរុបមកវិញចម្លាក់សត្វហេមពាន្តគេឆ្លាក់នៅតាមខឿនព្រះវិហារបីដូចជាការសន្មតបង្ហាញពីបរិវេណរបស់ស្ថានទេពដែលសត្វជាគ្រឿងសម្គាល់ ប៉ុន្តែអ្នកសាងបង្ហាញត្រឹមតែសត្វបក្សីមួយជំពូកប៉ុណ្ណោះ បើសេចក្ដីក្នុងគម្ពីរត្រៃភូមិមានជាច្រើនទៀត៖ ត្រាយលឿង ចាមរី គោក ស្មាន់ ស្វាន រមាំង ទ្រាយ ខ្ទីង បក្សី ដំរី១០ត្រកូល រាជសីហ៍៨ត្រកូល។

[៦] សូមអាន៖ กระทรวงวัฒนธรรม สมุดภาพไตรภูมิฉบับอักษรธรรมล้านนาและอักษรขอม กรุงเทพ ๒๕๔๗

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

# ឯកសារពិគ្រោះ

តូច ឈួង

១៩៩៤ បាត់ដំបងសម័យលោកម្ចាស់ (?)

ក្រុមប្រឹក្សានីតិកម្ម

២០២២ គម្ពីរត្រៃភូមិ ភ្នំពេញ

กระทรวงวัฒนธรรม

๒๕๔๗ สมุดภาพไตรภูมิฉบับอักษรธรรมล้านนาและอักษรขอม กรุงเทพ

กระทรวงวัฒนธรรม

๒๕๖๑ สมุดภาพสัตว์หิมพานต์ กรุงเทพ

សាស្ត្រាចន្ទគោរព នាងមុច្ចលិន

សាស្ត្រារាជកុល

សាស្ត្រាព្រះសមុទ្ទឃោស

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION